**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រដ្ឋបាលព្រៃឈើ
លេខចូល ១៥៨១
ថ្ងៃទី ០២.០៧.០៩

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ៣៤២៣ កសក ៨៩៣

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៩

# សេចក្តីជូនដំណឹង

## ស្តីពី ការនាំចេញ នាំចូលគ្រាប់ពូជរុក្ខជាតិព្រៃ ឬ ប្រភេទរុក្ខជាតិព្រៃ

ក្នុងគោលបំណងទប់ស្កាត់ការរាតត្បាតរបស់សត្វល្អិតចង្រៃនិងជំងឺឆ្លងនានាដែលធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ធនធានសេនេទិចធម្មជាតិក្នុងស្រុក និងអនុលោមតាមច្បាប់ស្តីពីព្រៃឈើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមជូនដំណឹងដល់អតិថិជន ឬក្រុមហ៊ុននានា ដែលមានបំណងនាំចេញនាំចូលគ្រាប់ពូជរុក្ខជាតិព្រៃ ឬប្រភេទរុក្ខជាតិព្រៃឱ្យបានជ្រាបថា :

១-ការនាំចេញនាំចូលគ្រាប់ពូជរុក្ខជាតិព្រៃ ឬ ប្រភេទរុក្ខជាតិព្រៃសម្រាប់តម្រូវការប្រើប្រាស់ដាំដុះ លក់ដូរ និងចែកចាយ ត្រូវឆ្លងកាត់ការត្រួតពិនិត្យតាមផ្លូវច្បាប់ និងសិក្សាស្រាវជ្រាវវាយតម្លៃពីរដ្ឋបាលព្រៃឈើ។ ដោយឡែកចំពោះគ្រាប់ពូជរុក្ខជាតិព្រៃ ឬ ប្រភេទរុក្ខជាតិព្រៃថ្មី តម្រូវឱ្យមានការដាំសាកល្បងជាចាំបាច់មុនការអនុញ្ញាតឱ្យនាំចូល ដើម្បីសិក្សាស្រាវជ្រាវអំពីផលប៉ះពាល់របស់វា។

២- អតិថិជន ឬ ក្រុមហ៊ុន ដែលមានបំណងស្នើសុំនាំចូលគ្រាប់ពូជរុក្ខជាតិព្រៃ ឬ ប្រភេទរុក្ខជាតិព្រៃសម្រាប់តម្រូវការប្រើប្រាស់ដាំដុះលក់ដូរ និងចែកចាយក្នុងប្រទេស និងទៅបរទេស ត្រូវធ្វើទំនាក់ទំនងព័ត៌មាន និងដាក់ពាក្យស្នើសុំទៅរដ្ឋបាលព្រៃឈើ អាសយដ្ឋានអគារលេខ ៤០ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារកណ្តាលទី ២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ឯកសារស្នើសុំត្រូវភ្ជាប់មកជាមួយនូវ :

ក- ពាក្យស្នើសុំនាំចេញនាំចូលគ្រាប់ពូជរុក្ខជាតិព្រៃ ឬ ប្រភេទរុក្ខជាតិព្រៃ។

ខ- លិខិតបញ្ជាក់អត្តសញ្ញាណរបស់អតិថិជន ឬ ក្រុមហ៊ុន។

គ- វិញ្ញាបនបត្រ ឬឯកសារទិដ្ឋាការគ្រាប់ពូជបញ្ជាក់ដោយអាជ្ញាធរវិទ្យាសាស្ត្រនៃប្រទេសនាំចេញ។

ឃ-វិញ្ញាបនបត្រភូតគាមអនាម័យនៃប្រទេសនាំចេញ និងសំណាកគ្រាប់ពូជរុក្ខជាតិព្រៃ ឬប្រភេទរុក្ខជាតិព្រៃ។

ក្រោយពីទទួលបានឯកសារស្នើសុំនាំចេញនាំចូលគ្រាប់ពូជរុក្ខជាតិព្រៃ ឬប្រភេទរុក្ខជាតិព្រៃ រដ្ឋបាលព្រៃឈើត្រូវធ្វើការពិនិត្យសិក្សាលើសំណុំឯកសារស្នើសុំនេះ រួចធ្វើរបាយការណ៍ជូនយោបល់សុំការសម្រេចពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

៣- អតិថិជន ឬ ក្រុមហ៊ុន ត្រូវដាក់ឯកសារស្នើសុំនាំចេញនាំចូលគ្រាប់ពូជរុក្ខជាតិព្រៃ ឬប្រភេទរុក្ខជាតិព្រៃ រយៈពេល ០៣ (បី)ខែ យ៉ាងតិចមុនពេលធ្វើការនាំចេញនាំចូលគ្រាប់ពូជរុក្ខជាតិព្រៃ ឬប្រភេទរុក្ខជាតិព្រៃ ។

ទទួលបានសេចក្តីជូនដំណឹងនេះ រដ្ឋបាលព្រៃឈើត្រូវចាត់ការអនុវត្តជូនអតិថិជន ឬក្រុមហ៊ុន ព្រមទាំងផ្សព្វផ្សាយអំពី នីតិវិធីនាំចេញនាំចូលគ្រាប់ពូជរុក្ខជាតិព្រៃ ឬ ប្រភេទរុក្ខជាតិព្រៃ ឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

**ចម្លងជូន:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គាធិការដ្ឋាន
- រដ្ឋបាលព្រៃឈើ ✓
- ឯកសារ-កាលប្បវត្តិ

ច័ន្ទ សារុន